# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ៩២៤ "ក្រ៥ ល"

ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩

-សំណុំរឿងព្រហ្មទណ្ឌលេខ ៧៩១

ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩

-សំណុំរឿងស៊ើបសួរលេខ ៤១៧

ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩

-សំណុំរឿងជំនុំជម្រះលេខ ២២៤៧

ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ វេលារសៀល នៅសាលសវនាការទី ៥ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សាជំនុំជម្រះ

### តំណាងអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៧៩១ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលមាន៖

-ជនជាប់ចោទឈ្មោះ [redacted] ទង ហៅ ធី ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិវៀតណាម សាសនាព្រះពុទ្ធ មុខរបរនេសាទ ទីកន្លែងកំណើតនៅសង្កាត់ជ្រោយចង្វារ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួននៅភូមិទំនប់ [redacted] មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] "រស់" ម្ដាយឈ្មោះ លង "រស់" ជានីតិជន ទោសពីមុនគ្មាន។

-ឃាត់ខ្លួន ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១០៩២ "ម" ដ.ឃ.ដ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩។

-មានលោកស្រីមេធាវី [redacted]កញ្ញា និងលោកមេធាវី [redacted]ម៉ានោ ជាមេធាវីការពារសិទ្ធិឱ្យ។

ជាប់ចោទពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ០៣ ផ្ទះសំណាក់ចន្ទរត្រជាក់ចិត្ត ភូមិឫស្សីទី០២ សង្កាត់ស្ទឹងមានជ័យទី០៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

-មានលោក [redacted]ម៉ានោ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ទង ហៅ ធី ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីមុំ ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរស៊ីឈ្នួលតាមផ្ទះ ទីកន្លែងកំណើតភូមិព្រៃសំបួរ ឃុំអង្គរបុរី ស្រុកអង្គរបុរី ខេត្តតាកែវ មានទីលំនៅបច្ចុប្បន្នភូមិព្រៃសំបួរ ឃុំអង្គរបុរី ស្រុកអង្គរបុរី ខេត្តតាកែវ (ជាប្រពន្ធរបស់ជនរងគ្រោះឈ្មោះ យ៉ាន់ ជឿន កើតថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៨១)។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៩ ជនរងគ្រោះឈ្មោះ [redacted] ជឿន ភេទប្រុស បានចេញពីផ្ទះនៅខេត្តតាកែវមកភ្នំពេញ ពេលនោះជនសង្ស័យឈ្មោះ [redacted] ទង ហៅ ធី ភេទប្រុស ក៏បានសុំគាត់មកជាមួយដើម្បីរកការងារធ្វើនៅ

Scanned with CamScanner

ភ្នំពេញ ហើយពេលធ្វើដំណើរតាមផ្លូវ ជនសង្ស័យបានរៀបរាប់ប្រាប់ជនរងគ្រោះថាឈ្មោះ[redacted]ផល្លា ដែលជាសង្សាររបស់ខ្លួន មិនស្មោះជាមួយខ្លួន ពេលនោះជនរងគ្រោះបានប្រាប់ជនសង្ស័យថាឈ្មោះ[redacted]ផល្លា មិនមែនជាមនុស្សល្អទេ ហើយថាគាត់ធ្លាប់រួមភេទជាមួយឈ្មោះ [redacted]ផល្លា នោះច្រើនដងមកហើយ ពេលឮដូចនេះជនសង្ស័យខឹងនឹងជនរងគ្រោះ ហើយឱ្យជនរងគ្រោះឈប់ម៉ូតូនៅផ្សារមួយមិនស្គាល់ឈ្មោះ រួចជនសង្ស័យបានចូលទៅក្នុងផ្សារនោះ និងបានទិញកាំបិតចុងស្រួចដងឈើមួយលាក់ទុកក្នុងកាតាប ហើយក៏ឡើងជិះម៉ូតូជាមួយជនរងគ្រោះ រួចបន្តដំណើរទៅភ្នំពេញ។ ពេលមកដល់ភ្នំពេញ ម៉ោងប្រហែល ១៤រសៀល ជនរងគ្រោះ និងជនសង្ស័យបានចូលទៅស្នាក់នៅផ្ទះសំណាក់ចន្ទ្រាត្រជាក់ចិត្តនៅមុំស្ពានដែកចំការដូង ដោយស្នាក់នៅបន្ទប់០៣ ហើយពេលទៅដល់ក្នុងបន្ទប់ជនរងគ្រោះបានឱ្យសោម៉ូតូទៅជនសង្ស័យ ហើយប្រើជនសង្ស័យឱ្យទៅដឹកស្រី ហើយពេលនោះជនសង្ស័យក៏បានសួរជនរងគ្រោះបញ្ជាក់ម្តងទៀតពីរឿងជនរងគ្រោះធ្លាប់រួមភេទជាមួយឈ្មោះ ទុំ ផល្លា ហើយជនរងគ្រោះបានប្រាប់ថាគាត់ពិតជាធ្លាប់មែន ពេលនោះជនសង្ស័យក៏បានដកកាំបិតដែលបានលាក់ទុកនោះចាក់ទៅលើខ្លួនរបស់ជនរងគ្រោះ ត្រូវចំទ្រូង និងពោះ ចំនួន ១០កន្លែង និងខ្នងចំនួន ០៧កន្លែង ហើយជនសង្ស័យចេញពីផ្ទះសំណាក់ខាងលើ ដោយជិះយកម៉ូតូរបស់ជនរងគ្រោះទៅលក់យកប្រាក់ ហើយគេចខ្លួនបាត់។ លុះមកដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩ ទើបសមត្ថកិច្ចស្រាវជ្រាវឃាត់ខ្លួនជនសង្ស័យខាងលើបាន។

-បានឃើញ របាយការណ៍សំយោគលេខ ០០៩/២០១៩ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ការិយាល័យសួរចម្លើយនិងនីតិវិធី នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៤៥២ អ.យ.ង ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ របស់លោក [redacted] ផេង តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលបានដាក់ជនជាប់ចោទឈ្មោះ [redacted] ទង ហៅ ធី ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ០៣ ផ្ទះសំណាក់ចន្ទ្រាត្រជាក់ចិត្ត ភូមិឫស្សីទី០២ សង្កាត់ស្ទឹងមានជ័យទី០៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

-បានឃើញ ដីកាសន្និដ្ឋានស្ពាពរលេខ ១៩៩៦ អ.យ.ង ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ របស់លោក[redacted] ផេង តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលប្តឹងសុំឱ្យចៅក្រមស៊ើបសួរបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ទង ហៅ ធី មកជំនុំជម្រះពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ០៣ ផ្ទះសំណាក់ចន្ទ្រាត្រជាក់ចិត្ត ភូមិឫស្សីទី០២ សង្កាត់ស្ទឹងមានជ័យទី០៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

-បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២៦២៧ "ម" ដ.ង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ របស់លោក [redacted] សៅ ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ហៅ ធី មកជំនុំជម្រះពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ០៣ ផ្ទះសំណាក់ចន្ទ្រាត្រជាក់ចិត្ត ភូមិឫស្សីទី០២ សង្កាត់ស្ទឹងមានជ័យទី០៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ទង បានឆ្លើយថា៖ ខ្លួនអត់ស្គាល់ជនរងគ្រោះទេ។ ថ្ងៃកើតហេតុជនរងគ្រោះបបួលខ្លួនមកភ្នំពេញមកប្រើប្រាស់គ្រឿងញៀន ក៏នាំគ្នាជិះម៉ូតូចេញពីតាកែវមកស្ពានដែកស្ទឹងមានជ័យគោលបំណងមកប្រើប្រាស់គ្រឿងញៀន ថ្នាំញៀនជារបស់ជនរងគ្រោះ ប្រើថ្នាំញៀននៅផ្ទះសំណាក់ចន្ទ្រាត្រជាក់ចិត្ត។ ជនរងគ្រោះនិយាយ



Scanned with CamScanner

ជាមួយខ្លួនថា គាត់ធ្លាប់ដេកជាមួយប្រពន្ធខ្លួនច្រើនដងហើយ។ ពេលចូលផ្ទះសំណាក់គាត់ក៏យកកាំបិតមកភ្ជង់ខ្លួន ហើយប្រតាយប្រតប់គ្នា ខ្លួនក៏ចាក់គាត់ ហើយក៏រត់តែមកម្តង។ ខ្លួនសារភាពថាខ្លួនបានសម្លាប់មែន តែកាំបិតមិនដឹងយកមកពីណាទេ គាត់សៀតនៅនឹងចង្កេះគាត់។ កាំបិតមិនមែនជារបស់ខ្លួនទេ។ ខ្លួនរស់នៅតាកែវដោយសារប្រពន្ធខ្លួនបបួលទៅ។ ពេលមកភ្នំពេញមិនបានឈប់នៅកន្លែងណាទេ។ ពេលសមត្ថកិច្ចយកចម្លើយខ្លួន គឺគេវាយខ្លួន ខ្លួនគ្មានទំនាស់អ្វីជាមួយសមត្ថកិច្ចទេ។ ពេលប្រើប្រាស់រួចជនរងគ្រោះឱ្យខ្លួនរកស្រីឱ្យគាត់ ហើយគាត់និយាយថាគាត់ធ្លាប់ដេកជាមួយប្រពន្ធខ្លួនប្រមាថខ្លួន។ ខ្លួនចាក់គាត់ហើយ ក៏ជិះម៉ូតូរបស់ជនរងគ្រោះរត់ ហើយយកទៅដាក់នៅផ្ទះមិត្តភក្តិខ្លួន ហើយគេឱ្យលុយខ្លួន ៥០០$។ ម៉ូតូនោះ គឺខ្លួនលក់ឱ្យមិត្តភក្តិខ្លួនឈ្មោះ បញ្ញារ៉ុង។ គាត់បាននិយាយប្រមាថហើយស្ទុះមកច្របាច់កខ្លួន។ ចម្លើយខ្លួនឆ្លើយពីមុនមិនពិតទេ។ ចម្លើយនៅតុលាការចំនួន ០២ដងនោះ គឺខ្លួនឆ្លើយដោយសារថ្នាំញៀន និងខ្លួនភិតភ័យ។ ខ្លួនមិនបានចូលទិញកាំបិតនៅផ្សារទេ។ ខ្លួនចាក់ជនរងគ្រោះ ០២ ទៅ ០៣កាំបិតប៉ុណ្ណោះ។ កាំបិត គឺគាត់សៀតចង្កេះ។ ជនរងគ្រោះពុំមានលុយអ្វីទេ។ ម៉ូតូម៉ាកសង់២០១៦ ទុកនៅក្រោមផ្ទះសំណាក់ គេយកលុយមុន។ ពេលចាក់មានឈាមប្រឡាក់លើខ្លួន ហើយខ្លួនដូរអាវ ដោយសារមាននៅក្នុងកាបូបស្ពាយ។ ដូរអាវហើយក៏ចុះទៅយកម៉ូតូទៅលក់ឱ្យមិត្តភក្តិ លក់បាន ៥០០$។ កាំបិតដងឈើ គឺជារបស់ជនរងគ្រោះ។ ថ្ងៃនោះខ្លួនឈ្លោះជាមួយប្រពន្ធ ហើយដើរជួបគាត់ក៏ជិះម៉ូតូមកភ្នំពេញ។ ខ្លួនមិនបានទិញកាំបិតនៅផ្សារទេ។ កាំបិតនោះជារបស់ គាត់និយាយរឿងដេកជាមួយប្រពន្ធខ្លួន។ ខ្លួនមិនបានលក់ម៉ូតូទេ គឺយកទៅផ្ញើទេ។ ពេលឡើងមក គឺជនរងគ្រោះបបួលខ្លួនមក កាំបិតជារបស់គាត់។ [redacted]

-សាក្សីឈ្មោះ [redacted] គាង បានឆ្លើយថា៖ ជនរងគ្រោះមានឈ្មោះ [redacted] ធឿន។ ខ្លួននៅអង្គបូរី។ ថ្ងៃកើតហេតុឃើញក្មួយខ្លួនបានម៉ូយដឹកចេញមកតែមិនដឹងទៅណាទេ ខ្លួនមិនស្គាល់អ្នកជិះពីក្រោយទេ។ ក្មួយមានប្រពន្ធកូនធំៗអស់ហើយ។ ម៉ូតូគាត់សេរីឆ្នាំ២០១៦ តម្លៃជាង ១,០០០$។ ខ្លួនក៏ធ្លាប់ដឹកគេមកភ្នំពេញដែរ។ ខ្លួនមិនស្គាល់អ្នកណាទេ។ ក្មួយខ្លួនមិនធ្លាប់ប្រើប្រាស់គ្រឿងញៀនទេ គាត់ស្លូតណាស់។ [redacted]

-សាក្សីឈ្មោះ [redacted] សារ៉ាត បានឆ្លើយថា៖ ខ្លួនមិនចាំថ្ងៃកើតហេតុទេ។ ខ្លួនមិននៅផ្ទះទេ ខ្លួនរវល់ទៅជើងឯកពីម៉ោង ០២ រហូតម៉ោង ០៤ទើបមកវិញ។ ម៉ោងជាង ០៥ទើបខ្លួនដឹងថាមានមនុស្សស្លាប់។ ពេលចូលបន្ទប់ជួលមានគ្នា ០២នាក់ ពេលស្លាប់ម៉ោងប្រហែល ០៥ល្ងាច។ ពេលឃើញគេស្លាប់ ខ្លួនក៏ទៅហៅប៉ូលិសប៉ុស្តិ៍មកធ្វើការ។ ផ្ទះសំណាក់ខ្លួន មិនបានកត់ឈ្មោះអ្នកជួលបន្ទប់ទេ។ ពេលស្លាប់មានក្របភ្លួយជាមួយ។ ផ្ទះសំណាក់មិនបានដាក់កាមេរ៉ាទេ។

-តុលាការឱ្យក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីមុំ ដែលបានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ (ឯកសារលេខ ១៣/៤)។

-តុលាការឱ្យក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted] សំរ៉ុង ដែលបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ (ឯកសារលេខ ១៣/៣)។

## សេចក្តីសន្និដ្ឋានបញ្ចប់សំណុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ការសាកសួរដេញដោលនាពេលសវនាការជនជាប់ចោទបានឆ្លើយបដិសេធថា កាំបិតមិនមែនជារបស់ខ្លួនទេ ប៉ុន្តែតាមចម្លើយដែលបានឆ្លើយកន្លងមកជាហូរហែតាំងពីកន្លែងដែលជួបជនរងគ្រោះនៅស្រុកអង្គរបូរី ជិះម៉ូតូមកជាមួយជនរងគ្រោះ គោលបំណងមកប្រើប្រាស់គ្រឿងញៀន ក្រោយមកពេលនៅក្នុងបន្ទប់ផ្ទះសំណាក់ ពេលប្រើប្រាស់គ្រឿងញៀនរួច ជនជាប់ចោទក៏បានយកកាំបិតចាក់ជន [redacted] រងគ្រោះ។ ផ្អែកតាមលទ្ធផលកោសលវិច័យឃើញថា ជនជាប់ចោទបានចាក់ចំនួន ១៧កាំបិត តែជនជាប់ចោទថាខ្លួនចា[redacted]តែ ០២ ទៅ ០៣កាំបិត ហើយក៏បានយកម៉ូតូជនរងគ្រោះទៅលក់ឱ្យមិត្តភក្តិបានលុយចំនួន៣០០$ រួមនឹងម៉ូតូកូនទា ០១

[redacted]



Scanned with CamScanner

គ្រឿងថែមទៀត សរុបតម្លៃ៥០០$។ អំពើរបស់ជនជាប់ចោទជាអំពើសម្លាប់មនុស្សពិតប្រាកដ។ តាមចម្លើយរបស់ជនជាប់ចោទនៅដំណាក់កាលសមត្ថកិច្ច ឃើញថា ជនជាប់ចោទបានឆ្លើយសារភាពថា ពេលខ្លួនជិះម៉ូតូមកភ្នំពេញជាមួយជនរងគ្រោះខ្លួនបានចូលទិញកាំបិត តែពេលសវនាការនេះជនជាប់ចោទបែរជាឆ្លើយបដិសេធថាពេលសួរចម្លើយ គឺសមត្ថកិច្ចបង្ខំខ្លួនឱ្យឆ្លើយ។ ចម្លើយបដិសេធនេះ គ្រាន់តែជាការដោះសារគ្មានមូលដ្ឋានផ្ទុយពីអង្គហេតុដែលខ្លួនបានរៀបរាប់នាពេលនេះ ម្យ៉ាងទៀតពេលធ្វើសកម្មភាពរួច ជនជាប់ចោទមិនមានការភិតភ័យទេ ថែមទាំងបានយកម៉ូតូរបស់ជនរងគ្រោះទៅលក់ទៀតផង សកម្មភាពនេះបង្ហាញពីចេតនារបស់ជនជាប់ចោទដែលបានគិតទុករួចរាល់ហើយ។ ហេតុនេះតំណាងអយ្យការស្នើសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរទុកនៅដដែល។

## សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

[redacted]ឈ្មោះ [redacted] ម៉ានោ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ផ្អែកតាមការដេញដោលនាពេលសវនាការនេះ ឃើញថាកូនក្ដីរបស់ខ្លួនមិនមានបំណងក្នុងការរៀបចំគម្រោងដើម្បីសម្លាប់ទេ គាត់គឺគ្រាន់តែសម្លាប់ដោយសារការរេរវាពីការជេរប្រមាថទៅលើប្រពន្ធរបស់ខ្លួនពីសំណាក់ជនរងគ្រោះ ហើយខ្លួនខឹងខ្លាំងពេកក៏បានទាញយកកាំបិតមកចាក់សម្លាប់ជនរងគ្រោះតែម្ដង។ ដូច្នេះខ្លួនស្នើសុំឱ្យតុលាការកែប្រែបទចោទប្រកាន់លើកូនក្ដីខ្លួនបាទពីបទឃាតកម្មគិតទុកជាមុន មកជាបទ ឃាតកម្ម វិញ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] ទង ហៅ ធី បាននិយាយសំដីចុងក្រោយបង្អស់ថា៖ សុំឱ្យតុលាការកាត់ទោសខ្លួនតិចៗ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានពាក្យបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់ចម្លើយ និងអំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្ដុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-ជនជាប់ចោទឈ្មោះ [redacted] ទង ហៅ ធី ត្រូវបានចៅក្រមស៊ើបសួរសម្រេចបញ្ជូនមកជំនុំជម្រះពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ០៣ ផ្ទះសំណាក់ចន្ទរត្រជាក់ចិត្ត ភូមិឫស្សី១០២ សង្កាត់ស្ទឹងមានជ័យទី០៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

២-តាមរបាយការណ៍សំយោគលេខ ០០៩/២០១៩ រ.ប.ក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ការិយាល័យសួរចម្លើយ នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ បានរាយការណ៍ថា កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ១១ និង ៤៧



Scanned with CamScanner

០០នាទីថ្ងៃត្រង់ ឈ្មោះ [redacted] ទង បានជិះម៉ូតូឌុប ម៉ាកហុងដា ឌ្រីម សេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០១៦ ពាក់ស្លាកលេខ ភ្នំពេញ 1FL-9986 ដែលមានម្ចាស់ម៉ូតូឈ្មោះ [redacted] ជឿន ភេទប្រុស អាយុប្រហែល ៣៧ឆ្នាំ ពីខេត្តតាកែវឆ្ពោះមករាជធានីភ្នំពេញ ដើម្បីទិញថ្នាំញៀន។ នៅតាមផ្លូវឈ្មោះ [redacted] ទង បាននិយាយប្រាប់អំពីដំណើររឿងសង្សាររបស់ខ្លួនជាស្ត្រីមេម៉ាយកូន ០២ ឱ្យឈ្មោះ [redacted] ជឿន ស្តាប់ ពេលនោះឈ្មោះ [redacted] ជឿន បានឆ្លើយប្រាប់ថា រូបគេក៏ធ្លាប់បានរួមភេទជាមួយស្ត្រីនោះជាច្រើនលើកផងដែរ។ ភ្លាមៗនោះឈ្មោះ [redacted] ទង មានចិត្តខឹងសម្បារយ៉ាងខ្លាំង ក៏ឱ្យឈ្មោះ [redacted] ជឿន ឈប់ម៉ូតូដើរចូលផ្សារ (មិនចាំឈ្មោះ) ទិញកូនកាំបិតដងឈើទុកជាប់ខ្លួនត្រៀមសម្លាប់ឈ្មោះ [redacted] ជឿន។ លុះនៅម៉ោង ១៤រសៀល ឈ្មោះ [redacted] ទង និងឈ្មោះ [redacted] ជឿន ធ្វើដំណើរដល់រាជធានីភ្នំពេញ បាននាំគ្នាចូលសម្រាកនៅផ្ទះសំណាក់ចន្ទរត្រជាក់ចិត្ត។ ពេលចូលដល់បន្ទប់ឈ្មោះ [redacted] ជឿន បានឱ្យឈ្មោះ [redacted] ទង យកម៉ូតូទៅដឹកស្រីយកមកដេក មុននឹងចេញពីបន្ទប់ឈ្មោះ [redacted] ទង បានសួរបញ្ជាក់ទៅកាន់ឈ្មោះ [redacted] ជឿន ថា បងឯងពិតជាបានដេកជាមួយសង្សាររបស់ខ្ញុំមែនអត់ ពេលនោះឈ្មោះ [redacted] ជឿន ឆ្លើយប្រាប់ថា ពិតប្រាកដមែន ភ្លាមៗនោះធ្វើឱ្យឈ្មោះ [redacted] ទង ដកកាំបិតចេញពីកាបូបចាក់លើដងខ្លួនឈ្មោះ [redacted] ជឿន ជាច្រើនលើកច្រើនសារបណ្តាលឱ្យស្លាប់តែម្តង។ ពេលធ្វើសកម្មភាពរួចហើយឈ្មោះ [redacted] ទង បានយកម៉ូតូជិះគេចខ្លួនចេញពីកន្លែងកើតហេតុទៅជួបមិត្តភក្តិរស់នៅផ្ទះជួលម្តុំចោមចៅ ដើម្បីយកម៉ូតូទៅលក់បានប្រាក់ចំនួន ៤៧០$ ហើយប្រាក់ទាំងអស់នោះឈ្មោះ [redacted] ទង បានចាយវាយអស់ហើយ។

៣-ជនជាប់ចោទឈ្មោះ [redacted] ទង ហៅ ធី បានឆ្លើយនាពេលសវនាការថា នៅថ្ងៃកើតហេតុជនរងគ្រោះបបួលខ្លួនមកភ្នំពេញមកប្រើប្រាស់គ្រឿងញៀន ពេលមកដល់ភ្នំពេញក៏នាំគ្នាចូលប្រើថ្នាំញៀននៅផ្ទះសំណាក់ចន្ទរត្រជាក់ចិត្ត ពេលចូលដល់ក្នុងបន្ទប់ផ្ទះសំណាក់ជនរងគ្រោះបាននិយាយប្រមាថប្រពន្ធខ្លួន ហើយស្ទុះមកច្របាច់កខ្លួន និងបានយក [redacted] កាំបិតមកភ្ជង់ខ្លួន រួចក៏មានការប្រតាយប្រតប់គ្នា ហើយខ្លួនក៏ចាក់ជនរងគ្រោះ រួចខ្លួនក៏ជិះម៉ូតូរបស់ជនរងគ្រោះរត់ និងយកទៅលក់ឱ្យមិត្តភក្តិខ្លួនឈ្មោះ បញ្ញារ៉ុង បានប្រាក់ ៥០០$។ ខ្លួនសារភាពថាខ្លួនបានសម្លាប់ជនរងគ្រោះមែន ប៉ុន្តែកាំបិតមិនមែនជារបស់ខ្លួនទេ គឺជនរងគ្រោះសៀតនៅនឹងចង្កេះគាត់។ ខ្លួនមិនបានចូលទិញកាំបិតនៅផ្សារទេ ខ្លួនចាក់ជនរងគ្រោះ ០២ ទៅ ០៣កាំបិតប៉ុណ្ណោះ។

៤-ចម្លើយរបស់ជនជាប់ចោទនាពេលសវនាការដូចមានលើកឡើងក្នុងចំណុចទី ៣ខាងលើនេះ គឺជនជាប់ចោទទទួលស្គាល់ថាបានសម្លាប់ជនរងគ្រោះ ដោយចាក់នឹងកាំបិតពិតមែន ប៉ុន្តែជនជាប់ចោទបានព្យាយាមបដិសេធថា ខ្លួនមិនបានចូលផ្សារទិញកូនកាំបិតទុកដើម្បីសម្លាប់ជនរងគ្រោះទេ កាំបិតដែលខ្លួនចាក់ជនរងគ្រោះនោះ គឺជាកាំបិតរបស់ជនរងគ្រោះដែលយកមកភ្ជង់ខ្លួនទៅវិញ។ [redacted] ឃើញថាចម្លើយរបស់ជនជាប់ចោទនេះជាចម្លើយដែលមិនមានមូលដ្ឋាន និងភស្តុតាងអាចឱ្យតុលាការជឿនោះទេ ផ្ទុយទៅវិញតាមចម្លើយសារភាពរបស់ជនជាប់ចោទខ្លួនឯងដែលបានឆ្លើយសារភាពនៅដំណាក់កាលសមត្ថកិច្ច, តំណាងអយ្យការ និងចៅក្រមស៊ើបសួរ គឺបានឆ្លើយបញ្ជាក់ច្បាស់ថា ដោយសារខឹងជនរងគ្រោះធ្លាប់ដេកជាមួយសង្សារខ្លួន ទើបខ្លួនបានចូលផ្សារទិញកូនកាំបិតយកមកទុកក្នុងកាបូប ដើម្បីសម្លាប់ជនរងគ្រោះ លុះពេលមកដល់ផ្ទះសំណាក់ចន្ទរត្រជាក់ចិត្ត នៅសង្កាត់ស្ទឹងមានជ័យ ខ្លួនក៏ដកកូនកាំបិតចេញពីក្នុងកាបូបចាក់ជនរងគ្រោះ ជាច្រើនកាំបិតបណ្តាលឱ្យជនរងគ្រោះដួលក្នុងផ្លុកឈាម នោះ ធ្វើឱ្យតុលាការមានជំនឿថា ជនជាប់ចោទពិតជាបានចូលផ្សារទិញកាំបិតយកមកទុកក្នុងកាបូប ដើម្បីត្រៀមសម្លាប់ជនរងគ្រោះ លុះមកដល់ទីតាំងកើតហេតុមានឱកាសល្អ ជនជាប់ចោទក៏បានដកកូនកាំបិតចេញពីក្នុងកាបូបចាក់ជនរងគ្រោះឈ្មោះ [redacted] ជឿន ជាច្រើនកាំបិតបណ្តាលឱ្យជនរងគ្រោះឈ្មោះ [redacted] ជឿន ស្លាប់នៅហ្នឹងកន្លែង។

Scanned with CamScanner

៥-តាមចម្លើយរបស់ជនជាប់ចោទដែលទទួលស្គាល់ថា ខ្លួនពិតជាបានសម្លាប់ជនរងគ្រោះឈ្មោះ [redacted] ជឿន, តាមការយល់ឃើញនៅក្នុងចំណុចទី ៤ខាងលើ, តាមរបាយការណ៍សំយោគលេខ ០០៩/២០១៩ រ.ប.ក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ការិយាល័យសួរចម្លើយ នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ និងតាមភស្តុតាងដែលមាននៅក្នុងសំណុំរឿង គឺជាអង្គហេតុ និងភស្តុតាងធ្វើឱ្យតុលាការជឿថា កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៩ នៅចំណុចបន្ទប់លេខ០៣ ផ្ទះសំណាក់ចន្ទ្រត្រជាក់ចិត្ត ភូមិឫស្សីទី០២ សង្កាត់ស្ទឹងមានជ័យទី០៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ពិតជាមានអង្គ [redacted] ហេតុអំពើដែលជនជាប់ចោទឈ្មោះ [redacted] ទង ត្រៀមកូនកាំបិតទុកក្នុងកាបូបសម្រាប់ចាក់សម្លាប់ជនរងគ្រោះឈ្មោះ [redacted] ជឿន លុះមកដល់កន្លែងកើតហេតុជនជាប់ចោទក៏បានយកកូនកាំបិតដែលត្រៀមទុកនោះយកមកចាក់ជនរងគ្រោះឈ្មោះ [redacted] ជឿន ជាច្រើនកាំបិត បណ្តាលឱ្យជនរងគ្រោះស្លាប់នៅហ្នឹងកន្លែងតែម្តង។

៦-តាមបញ្ញត្តិមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ បានចែងថា ឃាតកម្មគិតទុកជាមុន គឺជាអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬដោយការពួនស្ទាក់។ ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ។ ឃាតកម្មគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។ [redacted]

៧-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ទង ហៅ ធី បានធ្វើ គឺជាអំពើមានគម្រោងទិញកូនកាំបិតទុកក្នុងកាបូបដើម្បីចាក់សម្លាប់ជនរងគ្រោះ លុះមកដល់កន្លែងកើតហេតុជនជាប់ចោទក៏បានយកកូនកាំបិតដែលត្រៀមទុកនោះយកមកចាក់ជនរងគ្រោះ ឈ្មោះ [redacted] ជឿន ជាច្រើនកាំបិត បណ្តាលឱ្យជនរងគ្រោះស្លាប់នៅហ្នឹងកន្លែង ដែលអំពើរបស់ជនជាប់ចោទនេះមានធាតុផ្សំជាបទ ឃាតកម្មគិតទុកជាមុន ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

៨-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ [redacted] ទង ហៅ ធី ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ០៣ ផ្ទះសំណាក់ចន្ទ្រត្រជាក់ចិត្ត ភូមិឫស្សីទី០២ សង្កាត់ស្ទឹងមានជ័យទី០៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

៩-នាពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទឈ្មោះ [redacted]ង ហៅ ធី គឺជានីតិជន និងជាជនមានសមត្ថភាពពេញលេញក្នុងការយល់ដឹងពីអំពើរបស់ខ្លួន និងលទ្ធផលតាមផ្លូវច្បាប់ ដូច្នេះជនជាប់ចោទអាចទទួលខុសត្រូវអំពើរបស់ខ្លួនតាមផ្លូវច្បាប់បាន។

១០-អំពើដែលជនជាប់ចោទឈ្មោះ [redacted]ទង ហៅ ធី បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម និងទំនៀមទំលាប់ល្អរបស់សង្គមខ្មែរយ៉ាងធ្ងន់ធ្ងរ ព្រមទាំងប៉ះពាល់ដល់អាយុជីវិតរបស់ជនរងគ្រោះ និងប៉ះពាល់ដល់ជីវភាពរបស់នៅរបស់ក្រុមគ្រួសារជនរងគ្រោះផងដែរ។

១១-តាមសៀវភៅគ្រួសារលេខ ០៤ អ.រ ៩៩១៥ បង្ហាញឱ្យឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីមុំ គឺជាប្រពន្ធរបស់ជនរងគ្រោះឈ្មោះ យ៉ាន់ ជឿន ដូចនេះការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ [redacted] ស្រីមុំ ក្នុងការប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ៥,០០០$ នោះ ឃើញថាការទាមទារនេះស្របតាមមាត្រា ១៣, មាត្រា ១៤ និងមាត្រា ១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីតុលាការសម្រេចឱ្យដោយយោងតាមផលប៉ះពាល់ជាក់ស្តែងជាក់ស្តែងដែលក្រុមគ្រួសារជនរងគ្រោះទទួលរង តាមមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

១២-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន សុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល។ ការស្នើសុំនេះមានមូលដ្ឋានតាមផ្លូវច្បាប់ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

Scanned with CamScanner

១៣-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន សុំឱ្យតុលាការកែប្រែបទចោទប្រកាន់លើកូនក្តីខ្លួនបាទពីបទ ឃាតកម្មគិតទុកជាមុន មកជាបទ ឃាតកម្ម វិញ ។ ការស្នើសុំនេះមិនមានមូលដ្ឋានតាមផ្លូវច្បាប់ទេ គប្បីតុលាការមិនលើកយកមកពិចារណាក្នុងការសម្រេចសេចក្តីឡើយ។

១៤-ជនជាប់ចោទឈ្មោះ [redacted] ទង បាននិយាយសំដីចុងក្រោយថា៖ សុំឱ្យតុលាការកាត់ទោសខ្លួនតិចៗ។ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

## ហេតុដូច្នេះសម្រេច

[redacted]

១-ផ្តន្ទាទោសឈ្មោះ [redacted] ទង ហៅ ធី ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល អស់មួយជីវិត ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ចន្ទរត្រជាក់ចិត្ត ភូមិឫស្សី២ សង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យឈ្មោះ [redacted] ទង ហៅ ធី សងសំណងជំងឺចិត្តចំនួន ៤,០០០$ (បួនពាន់ដុល្លារអាមេរិក) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីមុំ យោងតាមបញ្ញត្តិមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ទង ហៅ ធី និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីមុំ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩។

ភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

“បានចម្លងត្រឹមត្រូវតាមច្បាប់ដើម”

ថ្ងៃអង្គារ ១៥រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ក្រឡាបញ្ជី**

[redacted]

Murder [redacted]

Scanned with CamScanner